**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...០២០៥...សហវ.ភជរ

# ប្រកាស
## ស្តីពី
## ការបង្កើតអង្គភាពគ្រប់គ្រងគម្រោង ដើម្បីអនុវត្តមូលនិធិអភិវឌ្ឍន៍ គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ព្រះរាជក្រឹត្យលេខ នស/រកត/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញប្រកាសលេខ ២៥៣ សហវ-ប្រក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

បង្កើតអង្គភាពគ្រប់គ្រងគម្រោង ដើម្បីអនុវត្តមូលនិធិអភិវឌ្ឍន៍គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន។

**ប្រការ២.-**

អង្គភាពគ្រប់គ្រងគម្រោង ដើម្បីអនុវត្តមូលនិធិអភិវឌ្ឍន៍គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឱម ម៉ាក់ធារិទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន (អ.រ.ជ.) | នាយកគម្រោង |
| ២- លោក | **ហង្ស ទុទ្ធិកា** | អគ្គនាយករង នៃ អ.រ.ជ. | ប្រធានគ្រប់គ្រងគម្រោង |
| ៣- លោក | **ឈឹម សុចរស្មី** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍គម្រោងនៃ អ.រ.ជ. | អនុប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោង |
| ៤- លោក | **ម៉ែន វិបុលស័ក្តិ** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍គម្រោង នៃ អ.រ.ជ. | អនុប្រធានគម្រោង |
| ៥- លោក | **អ៊ិន សាភាន** | ប្រធានការិយាល័យអភិវឌ្ឍន៍គម្រោង នាយកដ្ឋានអភិវឌ្ឍន៍គម្រោង នៃ អ.រ.ជ. | ប្រធានផ្នែកវាយតម្លៃ និងជ្រើសរើសគម្រោង |
| ៦- លោកស្រី | **មុត ច័ន្ទម៉ានិត** | ប្រធានការិយាល័យមូលនិធិអភិវឌ្ឍន៍គម្រោង នាយកដ្ឋានអភិវឌ្ឍន៍គម្រោង នៃ អ.រ.ជ. | ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ |
| ៧- លោក | **ទួន សុគន្ធវណ្ណា** | ប្រធានការិយាល័យគ្រប់គ្រងហានិភ័យ នាយកដ្ឋានអភិវឌ្ឍន៍គម្រោង នៃ អ.រ.ជ. | ប្រធានផ្នែកត្រួតពិនិត្យ និងតាមដានគម្រោង។ |

**ប្រការ៣.-**

អង្គភាពគ្រប់គ្រងគម្រោង ដើម្បីអនុវត្តមូលនិធិអភិវឌ្ឍន៍គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជននេះ មានមុខងារ និងភារកិច្ច ដូចខាងក្រោម÷

- គ្រប់គ្រង និងចាត់ចែងការងារហិរញ្ញវត្ថុ និងរដ្ឋបាលឱ្យស្របតាមនីតិវិធីដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីមូលនិធិអភិវឌ្ឍន៍គម្រោង ភ.រ.ជ.
- រៀបចំតម្រូវការថវិកាសម្រាប់មូលនិធិអភិវឌ្ឍន៍គម្រោង ភ.រ.ជ.
- ផ្តល់ការគាំទ្រដល់ក្រសួង-ស្ថាប័នសាមីក្នុងការរៀបចំស្នើសុំថវិកាពីមូលនិធិ តាមការចាំបាច់
- ពិនិត្យ និងវាយតម្លៃសំណើសុំមូលនិធិរបស់ក្រសួង-ស្ថាប័នសាមីសម្រាប់សេវាទីប្រឹក្សា និងផ្តល់អនុសាសន៍ជូនគណៈកម្មការវិនិយោគសាធារណៈ ដើម្បីពិនិត្យ និងសម្រេច
- ផ្ទៀងផ្ទាត់ និងរៀបចំនីតិវិធីនៃសំណើសុំទូទាត់ទទួលបានពីទីប្រឹក្សា
- គ្រប់គ្រងហិរញ្ញវត្ថុនៃមូលនិធិក្នុងគណនីមូលនិធិអភិវឌ្ឍន៍គម្រោង ភ.រ.ជ.

- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់មូលនិធិខាងលើ

- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍជំនាញពាក់ព័ន្ធនឹងការរៀបចំអភិវឌ្ឍន៍គម្រោង ភ.រ.ជ.

- រៀបចំសិក្ខាសាលា, ទស្សនកិច្ចសិក្សា, កិច្ចប្រជុំ, កំណត់ហេតុអង្គប្រជុំ ព្រមទាំងធ្វើសេចក្តីជូនដំណឹងស្តីពីការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅកាន់ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ

- បំពេញការងារពាក់ព័ន្ធផ្សេងទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតម្រូវការចាំបាច់របស់មូលនិធិអភិវឌ្ឍន៍គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច, ឯកឧត្តម, លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ